00181297

C2d I/17

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២) |
| បញ្ជូនទៅ: | អង្គបុរេជំនុំជម្រះ |
| កាលបរិច្ឆេទនៃការបញ្ជូនៈ | ២៥ មេសា ២០០៨ |
| ភាគីបញ្ជូនៈ | សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី |
| ភាសាដើមៈ | ខ្មែរ និងអង់គ្លេស |
| ប្រភេទឯកសារៈ | សាធារណៈ |

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 25 / 04 / 2008
ម៉ោង (Time/Heure): 10:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

# ការឆ្លើយតបរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន

---

<u>**បញ្ជូនដោយ :**</u>

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោក ហុង គីមសួន

លោក ឡោ ជុនធី

លោក នី ចាន់ឌី

លោកស្រី Silke Studzinsky

<u>**ចែកចាយជូន :**</u>

**អង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គីមសាន

លោក Rowan DOWNING

លោក ន៍យ ថុល

លោកស្រី Katinka LAHUIS

លោក ហួត វុទ្ធី

**មេធាវីការពារអ្នកស្រី អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

កញ្ញា Dianna ELLIS

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 25 / 04 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

## I- សាវតានីតិវិធី

១. នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៧ ការិយាល័យសហចៅក្រមស៊ើបអង្កេត (ហៅថា ក.ស.ច.ស) បានចេញដីកាឃុំខ្លួនបណ្ដោះអាសន្ន (ហៅថា ដីកា) ប្រឆាំងនឹងអ្នកស្រី អៀង ធីរិទ្ធ សំរាប់រយៈពេលមិនឱ្យលើសពីមួយឆ្នាំ ។

២. នៅថ្ងៃទី ២ ខែ មករា ឆ្នាំ ២០០៨ ជនត្រូវចោទបានប្ដឹងឧទ្ធរណ៍ (ហៅថា បណ្ដឹងឧទ្ធរណ៍) ប្រឆាំងនឹងដីកានេះ ដែលត្រូវជំនួសដោយការបកស្រាយពីថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០០៨ ហើយបានស្នើសុំឱ្យមានការដោះលែងបណ្ដោះអាសន្នតាមលក្ខខណ្ឌទាំងឡាយណាដែលចាត់ទុកថាជាការត្រឹមត្រូវ ។

៣. អង្គបុរេជំនុំជម្រះ (ហៅថា អ.ប.ជ) បានសំរេចពីថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៨ ស្ដីពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការបណ្ដឹងឧទ្ធរណ៍នៃការឃុំខ្លួនបណ្ដោះអាសន្ន ហើយបានបង្គាប់ឱ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០០៨ រៀបចំចម្លើយតបមួយនៅក្នុងរយៈពេល ១៥ថ្ងៃ។ អ.ប.ជ បានជូនដំណឹងអំពីសេចក្ដីបង្គាប់ដល់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីរហូតដល់ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៨។ ដោយសារតែមានការជូនដំណឹងយឺត សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំពន្យាពេលកំណត់ការដាក់សារណាកាលពីថ្ងៃទី ៧ ខែ មេសា ២០០៨ ។ សំណើនេះត្រូវបានអនុញ្ញាតពន្យាពេលដាក់សារណារហូតដល់ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៨[១] ។
សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សូមជូនភ្ជាប់មកនូវសារណាតបរួមមួយចំពោះបណ្ដឹងឧទ្ធរណ៍នេះ ។

## II. សង្ខេបនៃរឿងក្ដី

៤. ឆន្ទានុសិទ្ធិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវបានគេអនុវត្តយ៉ាងត្រឹមត្រូវ ហើយបង្ហាញថាមានមូលដ្ឋានសមហេតុផលនិងអាចទទួលយកបាន ។ បណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារមិនបានបង្ហាញឱ្យឃើញថា មានកំហុសឆ្គងនៅក្នុងដីកាឃុំខ្លួននោះទេ ។
អនុលោមតាមវិធាន៦៣ (៣) ចំនុច (ក) មានមូលហេតុដែលត្រូវបានគេរកឃើញ និងជឿជាក់យ៉ាងច្បាស់ថាជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ដូចមានចែងលំអិតនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។ លើសពីនេះទៅទៀត ដីកាឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ដើម្បី

---

[១] សេចក្ដីសម្រេចរបស់ អ.ប.ជ ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០០៨ ឯកសារតុលាការ (C20/I/16)

00181299

C20/I/17

រារាំងកុំឱ្យជនត្រូវចោទគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ រក្សាសណ្តាប់ធ្នាប់សាធារណៈ ការពារសុវត្ថិភាពខ្លួនគាត់និងធានាវត្តមានរបស់ជនត្រូវចោទនៅក្នុងការជំនុំជម្រះនាពេលខាងមុខ ។ ដីកានេះស្របទៅនឹងលក្ខខណ្ឌនៃវិធាន ៦៣ (៣) ចំនុច (ខ)ពីលេខ ១-៥។

## III. អង្គហេតុពាក់ព័ន្ធ

៥. នៅក្នុងបណ្តឹងឧទ្ធរណ៍ ជនត្រូវចោទបានលើកទឡ្ហីករណ៍ថា :

(១) ដីកានេះមិនបានផ្អែកទៅលើមូលដ្ឋានសមហេតុសមផល នាំឱ្យជឿថាជនត្រូវចោទអាចប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរ ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ផ្ទុយទៅវិញ ជនត្រូវចោទបានបដិសេធមិនទទួលខុសត្រូវហើយអង្គហេតុដែលយោងក្នុងដីកានេះគឺ " មិនពិត១០០ភាគរយ" និងបានអះអាងថាការបំពេញការងាររបស់ជនត្រូវចោទកន្លងមកគឺដើម្បីផលប្រយោជន៍របស់ប្រជាជនតែប៉ុណ្ណោះ[២] ។

(២) គ្មានមូលដ្ឋានណាដែលបង្ហាញថា ជនត្រូវចោទមានបំណងរត់គេចខ្លួននោះទេ ហើយគាត់ក៏បានបង្ហាញថានៅពេលដែលគាត់ដឹងពីការបង្កើត អ.វ.ត.ក ហើយដឹងថារូបគាត់នឹងត្រូវចាប់ខ្លួននៅពេលខាងមុខក៏ដោយ ក៏ជនត្រូវចោទមិនបានរត់គេចខ្លួននោះដែរ ហើយប្រសិនបើទៅបរទេសជនត្រូវចោទក៏តែងតែត្រឡប់មកវិញ[៣] ។

(៣) ការដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន មិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈទេ ចំណែកឯ សុវត្ថិភាពផ្ទាល់ខ្លួនរបស់ជនត្រូវចោទក៏មិនស្ថិតនៅក្នុងគ្រោះថ្នាក់ដែរ ទោះបីជនត្រូវចោទរស់នៅដោយការដឹងជាចំហដោយសាធារណៈជនក៏ដោយ[៤] ។

(៤) ដីការបស់សហចៅក្រមស៊ើបអង្កេត មិនបានបង្ហាញភស្តុតាងណាមួយដែលថាជនត្រូវចោទអាចគាបសង្កត់ដល់សាក្សី និងជនរងគ្រោះ ហើយជនត្រូវចោទក៏គ្មានបំណងធ្វើបែបនេះដែរ[៥] ។

(៥) ស្ថានភាពសុខភាពរបស់ជនត្រូវចោទ គឺទន់ខ្សោយ[៦] ។

---

[២] សូមមើលកថាខ័ណ្ឌ ១១ នៃបណ្តឹងឧទ្ធរណ៍

[៣] សូមមើលកថាខ័ណ្ឌ ១៧ និង ៤០ នៃបណ្តឹងឧទ្ធរណ៍

[៤] សូមមើលវាក្យខ័ណ្ឌពីលេខ៤៣ ដល់ ៤៧ នៃបណ្តឹងឧទ្ធរណ៍

[៥] សូមមើលវាក្យខ័ណ្ឌពីលេខ៤៨ ដល់ ៥៤ នៃបណ្តឹងឧទ្ធរណ៍

00181300



## IV. វិសាលភាពនៃបណ្តឹងឧទ្ធរណ៍ និងតួនាទីរបស់អង្គបុរេជំនុំជម្រះ

៦. នៅក្នុងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិអតីតយូហ្គោស្លាវី គេទទួលស្គាល់ថាសភាជំនុំជម្រះអនុវត្តឆន្ទានុសិទ្ធិក្នុងស្ថានភាពផ្សេងៗជាច្រើនដូចជា ជំនុំជម្រះផ្តន្ទាទោស សំរេចឱ្យនៅក្រៅឃុំ ការអនុញ្ញាតទទួលយកប្រភេទភស្តុតាងមួយចំនួន ការវាយតម្លៃភស្តុតាង និង (ញឹកញាប់ជាងនេះ) សម្រេចលើចំណុចនានាស្តីពីការអនុវត្ត ឬនីតិវិធី[៧] ។

៧. ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក មានមុខនាទីចេញដីកាឃុំខ្លួនបណ្តោះអាសន្ន ឬការដោះលែងក្រៅឃុំបណ្តោះអាសន្ន ដូចគ្នាទៅនឹងសភាជំនុំជម្រះនៅសាលាក្តីព្រហ្មទណ្ឌអន្តរជាតិអតីតយូហ្គោស្លាវី ហើយប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនដូចគ្នាអញ្ចឹងដែរ ។ អង្គបុរេជំនុំជម្រះមានសមត្ថកិច្ចចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ហើយបើប្រៀបធៀបទៅវាដូចគ្នាទៅនឹងសភាសាលាឧទ្ធរណ៍នៃតុលាការអន្តរជាតិនានា[៨] ។

៨. នៅពេលមានបណ្តឹងឧទ្ធរណ៍ទាក់ទងទៅនឹងសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិរបស់សភាជំនុំជម្រះ បញ្ហាក្នុងបណ្តឹងឧទ្ធរណ៍នោះ គឺថាតើសេចក្តីសំរេចនោះត្រឹមត្រូវ ឬអត់ ។ មានន័យថាសភាជាន់ខ្ពស់ឯកភាពនឹងសេចក្តីសម្រេចនេះ ប៉ុន្តែជាងនេះទៅទៀតសភាជំនុំជម្រះបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនត្រឹមត្រូវក្នុងការសម្រេចចិត្តនេះ ។ ប្រសិនបើសភាជំនុំជម្រះបានអនុវត្តន៏ឆន្ទានុសិទ្ធិរបស់ខ្លួនបានត្រឹមត្រូវ នោះសេចក្តីសម្រេចរបស់ខ្លួន វាមិនប៉ះពាល់ដល់បណ្តឹងឧទ្ធរណ៍នោះទេ ទោះបីជាយ៉ាងណាក៏ដោយសភាជាន់ខ្ពស់អាចអនុវត្តន៏ឆន្ទានុសិទ្ធិរបស់ខ្លួនផ្សេងពីនេះក៏បាន ។ បញ្ហានេះវាសំខាន់ណាស់ចំពោះការសម្រេចចិត្តណាមួយតាមឆន្ទានុសិទ្ធិ ។ តែបើកន្លែងណាមានកំហុសក្នុងការអនុវត្តអំណាចឆន្ទានុសិទ្ធិ

---

[៦] សូមមើលវាក្យខណ្ឌ១៧ (ចំនុច៤) និងរបាយការណ៍ពេទ្យក្នុងឧបសម្ព័ន្ធ ក នៃបណ្តឹងឧទ្ធរណ៍

[៧] ព្រះរាជអាជ្ញាលោក v. Milosevic, មូលហេតុចំពោះសេចក្តីសម្រេចស្តីពី ការកាត់សេចក្តីបណ្តឹងឧទ្ធរណ៍ដែលសម្រេចនៃពេលប្តឹង ពីការបដិសេធចំពោះដីការួមគ្នា រឿងក្តីលេខ IT-99-37-AR73 និង IT-01-50-AR73 និង IT-01-51-AR73 ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២ (ហៅថា ការបដិសេធចំពោះដីការួមគ្នា) សូមមើលវាក្យខ័ណ្ឌ៣

[៨] ប្រាកដច្បាស់មែនទែនទាក់ទងទៅនឹងចំនុចដែរបានរៀបរាប់ខាងលើៈ ព្រះរាជអាជ្ញាលោក v. Milosevic Fofana រឿងក្តីលេខ SCSL-04-14-AR65 បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចដែលបដិសេធការសុំនៅក្រៅឃុំបណ្តោះអាសន្ន ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០០៥ វាក្យខ័ណ្ឌ២០ ដែលសភាជំនុំជម្រះកត់សំគាល់អំពី "មុខងាររបស់ចៅក្រម ឬសភាជំនុំ ជម្រះ" ក្នុងការផ្តល់ឱ្យនៅក្រៅឃុំបណ្តោះអាសន្ន (សូមមើលការបញ្ជាក់បន្ថែម)

គេត្រូវតែបង្ហាញឱ្យឃើញថា សភាជាន់ខ្ពស់អាចអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនជំនួសឱ្យឆន្ទានុសិទ្ធិដែលអនុវត្តនៅសភាជំនុំជម្រះ[៩] ។

៩. សេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតចំពោះដីកាឃុំខ្លួនបណ្តោះអាសន្ន គឺជាសេចក្តីសម្រេចឆន្ទានុសិទ្ធិ ហើយអង្គបុរេជំនុំជម្រះគ្រាន់តែសម្រេចថាតើចៅក្រមស៊ើបអង្កេត " បានអនុវត្តឆន្ទានុសិទ្ធិតាមទស្សនៈរបស់ខ្លួនត្រឹមត្រូវ ឬអត់ "[១០] ។

នៅតុលាការពិសេសសំរាប់សេរ៉ាលេអូន (SCSL) តុលាការជាន់ខ្ពស់បានលើកឡើងថា " ចៅក្រម ឬសភាជំនុំជម្រះ" អនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការផ្តល់ ឬបដិសេធការឱ្យនៅក្រៅឃុំបណ្តោះអាសន្ន។ សភាជាន់ខ្ពស់នឹងមិនប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ជំនួសឱ្យការអនុវត្តឆន្ទានុសិទ្ធិដ៏ត្រឹមត្រូវរបស់ចៅក្រម ឬសភាជំនុំជម្រះនោះទេ[១១] ។

ភាគីទាំងឡាយដែលប្រឈមមុខនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ឬសេចក្តីសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នត្រូវទទួលបន្ទុកក្នុងការបង្ហាញថាចៅក្រមបានប្រព្រឹត្តនូវ "កំហុសដោយបំពាន"[១២] ។

១០. សភាជាន់ខ្ពស់នឹងច្រានចោលនូវសេចក្តីសំរេចស្តីពី ការដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នរបស់សភាជំនុំជម្រះ បានតែនៅពេលណាដែលគេយល់ឃើញថា (១)ផ្អែកលើការបកស្រាយមិនត្រឹមត្រូវ

---

[៩] ព្រះរាជអាជ្ញា v. Milosevic, ការបដិសេធចំពោះដីការួមគ្នា វាក្យខ័ណ្ឌ៣

[១០] ព្រះរាជអាជ្ញា v. Stanisic រឿងក្តីលេខ.IT-04-79-AR65.I សេចក្តីសម្រេចស្តីពី ការកាត់ទោសបណ្តឹងឧទ្ធរណ៍ដែលសម្រេចនៅពេលប្តឹង អំពីការដោះលែងបណ្តោះអាសន្នរបស់ Mico Stanisic ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៥ វាក្យខ័ណ្ឌ ៦

ព្រះរាជអាជ្ញា v. Boskoski និង Tarculovski រឿងក្តីលេខ IT-04-82-AR65.2 សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍អំពីការដោះលែងបណ្តោះអាសន្នម្រេចនៅពេលប្តឹងរបស់ Ljube Boskoski ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៥ វាក្យខ័ណ្ឌ៥

[១១] ព្រះរាជអាជ្ញា v. Moinina Fofana រឿងក្តីលេខ SCSL-០៤-១៤-AR65 បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេចដែលបដិសេធការនៅក្រៅឃុំបណ្តោះអាសន្ន

[១២] ដូចចំនុចខាងលើ

នៃច្បាប់ដែលនៅជាធរមាន (២) ផ្អែកលើសេចក្តីសន្និដ្ឋាននៃអង្គហេតុមិនត្រឹមត្រូវ ឬ (៣) មិនយុត្តិធម៌ ឬមិនសមហេតុផលរហូតដល់បង្កឱ្យមានការរំលោភបំពាននៃឆន្ទានុសិទ្ធិរបស់សភាជំនុំជម្រះ[១៣] ។

១១. ដើម្បីច្រានចោលសេចក្តីសម្រេចរបស់សភាជំនុំជម្រះបាន សភាជាន់ខ្ពស់ត្រូវបង្ហាញថាសភាជំនុំជម្រះ (១) ប្រើប្រាស់ខុសខ្លួនឯងចំពោះគោលការណ៍ដែលត្រូវបានអនុវត្ត (២) ប្រើប្រាស់ខុសខ្លួនឯងចំពោះច្បាប់ដែលពាក់ព័ន្ធទៅនឹងការអនុវត្តឆន្ទានុសិទ្ធិ (៣) បានដាក់ទម្ងន់ក្នុងការពិចារណាដែលគ្មានពាក់ព័ន្ធ ឬទាក់ទង (៤) មិនបានផ្តល់ទម្ងន់ ឬមានទម្ងន់គ្រប់គ្រាន់ចំពោះការពិចារណាពាក់ព័ន្ធ (៥)បានប្រព្រឹត្តកំហុសចំពោះអង្គហេតុដែលសភាជាន់ខ្ពស់បានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ឬ (៦)បានចេញសេចក្តីសម្រេច"មិនសមហេតុផល ឬយុត្តិធម៌ពេករហូតដល់សភាជាន់ខ្ពស់អាចទាញសេចក្តីសន្និដ្ឋានថាសភាជំនុំជម្រះប្រាកដជាមិនបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនបានត្រឹមត្រូវ"[១៤] ។

សភាជាន់ខ្ពស់នៅ (SCSL) បានកត់សំគាល់ថា សភាជាន់ខ្ពស់អាចបដិសេធសេចក្តីសម្រេចបានលុះណាតែសេចក្តីសម្រេចនោះផ្ទុយនឹងសីលធម៌ពិតប្រាកដ ឬមិនអាចទទួលយកបាន[១៥] ។

១២. សភាជំនុំជម្រះមិនតំរូវឱ្យពិចារណាកត្តាដែលអាចធ្វើទៅបានទេ ហើយត្រូវពិចារណានូវស្ថានភាពពិសេសៗនៃរឿងក្តីនីមួយៗ ទោះបីជាយ៉ាងណាក៏ដោយសភាជំនុំជម្រះត្រូវចេញសេចក្តីសម្រេចដែលមានមូលហេតុត្រឹមត្រូវ[១៦] ។

---

[១៣] ព្រះរាជអាជ្ញា v. Milosevic រឿងក្តីលេខ.IT-02-54-AR73.7 សេចក្តីសម្រេចស្តីពី បណ្តឹងឧទ្ធរណ៍ដែលសម្រេចនៅពេលប្តឹងនៃសេចក្តីសម្រេចរបស់សភាជំនុំជម្រះស្តីពីការងាររបស់មេធាវីការពារចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៤ វាក្យខ័ណ្ឌ១០

[១៤] ព្រះរាជអាជ្ញា v. Tolimir et al, រឿងក្តីលេខ.IT-04-80-AR65.1 សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ដែលសម្រេចនៅពេលប្តឹងប្រឆាំងនឹងសេចក្តីសម្រេចរបស់សភាជំនុំជម្រះដែលផ្តល់ការដោះលែងបណ្តោះអាសន្ន ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០០៥ វាក្យខ័ណ្ឌ៤ ដែលយោងទៅរកព្រះរាជអាជ្ញា v. Milosevic រឿងក្តីលេខ IT-02-54-AR73.7 សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ដែលសម្រេចនៅពេលប្តឹងនៃសេចក្តីសម្រេចរបស់សភាជំនុំជម្រះស្តីពីការងាររបស់មេធាវីការពារចុះថ្ងៃទី១ ខែវិច្ឆិកា ២០០៤ វាក្យខ័ណ្ឌ៥

[១៥] ចូរមើលលេខយោងទី១០

[១៦] ព្រះរាជអាជ្ញា v. Nikola Sainiovic and Dragoljub Ojdanic រឿងក្តីលេខ IT-93-37-AR65 សេចក្តីសម្រេច ស្តីពីការដោះលែងបណ្តោះអាសន្ន ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០០២ វាក្យខ័ណ្ឌ៦

១៣. ដូច្នេះ គេត្រូវបង្ហាញឱ្យឃើញថាវិសាលភាពនៃបណ្ដឹងឧទ្ធរណ៍ និងតួនាទីរបស់អង្គបុរេជំនុំជម្រះត្រូវបានកំណត់យ៉ាងត្រឹមត្រូវ ។

## V- ច្បាប់ដែលពាក់ព័ន្ធ

១៤. យោងតាមវិធាន ៦៣ (៣) នៃវិធានផ្ទៃក្នុង (ហៅថាវ.ផ.ក) សហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទបានតែក្នុងលក្ខខ័ណ្ឌដូចខាងក្រោម :

ក- មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬ ច្រើនដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានរឿងឱ្យស៊ើបសួរបន្ថែម ។

ខ- សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ដើម្បី :

(១) រារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ឬ រារាំងកុំឱ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

(២) ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង ។

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី ។

(៤) ការពារសន្តិសុខឱ្យជនដែលត្រូវចោទ ឬ

(៥) រក្សាសណ្ដាប់ធ្នាប់សាធារណៈ ។

១៥. ពាក្យ "ឬ" នៅចុងវិធាន(ខ) (ចំណុច៤) គូសបញ្ជាក់ថារាល់ចំនុចនិមួយៗនៅក្រោមលេខ (១-៥) ត្រូវមានការយល់ដឹងអំពីជំរើស ហើយមិនត្រួតលើគ្នាទេដើម្បីវាយតម្លៃប្រសិនបើការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការចំបាច់ ។ ការអនុវត្តលក្ខខ័ណ្ឌមួយដែលមានការរៀបរាប់នេះ គឺគ្រប់គ្រាន់ ។

## VI- ការពិនិត្យអំពីទស្សនៈពាក់ព័ន្ធរបស់មេធាវីការពារ

១៦. ដូចបានគូសបញ្ជាក់ខាងលើ ដីកាឃុំខ្លួនបណ្ដោះអាសន្នដែលជាសេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិ ត្រូវតែស្របទៅនឹងស្តង់ដារនៃសាលាក្ដីអន្តរជាតិផ្សេងទៀត និង ច្បាប់ជាតិនិងអន្តរជាតិ ហើយត្រូវតែ

ពិនិត្យឡើងវិញដោយយោងទៅតាមលក្ខណៈវិនិច្ឆ័យ ប្រសិនបើដីកានោះជាសេចក្តីសំរេចសមហេតុផល ហើយបើឆន្ទានុសិទ្ធិត្រូវគេអនុវត្តបានត្រឹមត្រូវ ។

១៧. បណ្តឹងឧទ្ធរណ៍មិនបានទាក់ទងទៅនឹងចំនុចដែលបានលើកឡើងខាងលើនេះ ហើយក៏មិនបានវិភាគថា តើការិយាល័យសហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តខុសទៅនឹងអង្គហេតុ ឬអង្គច្បាប់។ បន្ថែមពីលើនេះទៀត បណ្តឹងនេះទាមទារឱ្យជំនួសនូវឆន្ទានុសិទ្ធិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលបានអនុវត្តដោយជំនួសឆន្ទានុសិទ្ធិរបស់អង្គបុរេជំនុំជម្រះ ។

១៨. ចំពោះបញ្ហានេះ ប្រសិនបើមានមូលហេតុសមហេតុផលដែលអាចជឿថាជនត្រូវចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានកំណត់ជាក់លាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នោះមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ស្របតាមបណ្តឹងរបស់សហព្រះរាជអាជ្ញា[១៧] ។

**ក- ការសន្មត់ទុកជាមុនថាគ្មានទោស[១៨]**

១៩. គោលការណ៍ទូទៅនៃការសន្មត់ទុកជាមុនថាគ្មានទោស គឺមិនត្រូវបានគេរំលោភបំពានទាល់តែសោះដោយសេចក្តីថ្លែងក្នុងដីកាដែលថា "មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថាជនត្រូវចោទបានប្រព្រឹត្តបទឧក្រិដ្ឋដែលគេចោទប្រកាន់ពិតប្រាកដមែន" ។ ផ្ទុយទៅវិញ គោលការណ៍នេះ គឺជាសេចក្តីថ្លែងរបស់វិធាន៦៣ (៣) (ចំណុចក) ហើយកិច្ចការរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវវាយតម្លៃភស្តុតាងនៅក្នុងតំណាក់កាលនេះ ហើយត្រូវធ្វើសេចក្តីសន្និដ្ឋានប្រសិនបើមានមូលហេតុសមស្របនៃការមន្ទិលសង្ស័យដ៏ជឿជាក់ ។

មេធាវីការពារខកខានក្នុងការអះអាងរបស់ខ្លួនថា មានការរំលោភនៃគោលការណ៍ទូទៅទេ ។

**ខ- សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពបុគ្គល[១៩]**

២០. មេធាវីការពារផ្តល់ទឡ្ហីករណ៍ថា ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនផ្តល់ភស្តុតាងដើម្បីចង្អុលបង្ហាញការអះអាងរបស់ខ្លួនថាការដោះលែងជនត្រូវចោទអាចថា "នៅក្នុងបរិបទដ៏ផុយស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន ការគ្រោះថ្នាក់ដែលបង្កឱ្យមានការប្រឆាំងតវ៉ានៃការឈឺចាប់អាចនាំទៅដល់អំពើហឹង្សា" ហើយប្រហែលជាអាច "ធ្វើឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃជនត្រូវចោទតែម្តង" ។

---

[១៧] ចូរមើលវាក្យខ័ណ្ឌពីលេខ១៩ ដល់ ២១ និង២២

[១៨] ចូរមើលវាក្យខ័ណ្ឌពីលេខ៤១ ដល់ ៤២ នៃបណ្តឹងឧទ្ធរណ៍

[១៩] ចូរមើលវាក្យខ័ណ្ឌពីលេខ៤៣ ដល់ ៤៧ នៃបណ្តឹងឧទ្ធរណ៍

ដើម្បីប៉ាន់ប្រមាណនៃការគ្រោះថ្នាក់ដ៏ធំធេងនេះចំពោះសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពជនត្រូវចោទ ជានិច្ចកាលវាគឺជាចំណោទនៃភាពអាចនឹងកើតមាន និងភាពស្មើគ្នានៃស្ថានភាពដែលផ្តល់ឱ្យ។ ទោះបីជាការិយាល័យសហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញសេចក្តីលំអិត ឬអង្គហេតុដើម្បីបង្ហាញឱ្យឃើញថា ការគ្រោះថ្នាក់ដែលគេជឿជាក់ក្នុងចំណោទនេះយ៉ាងណាក៏ដោយ ក៏វាជាភស្តុតាងច្បាស់គួរសមដែរ ដែលថានៅក្នុងបរិបទដ៏ផុយស្រួយក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ការគ្រោះថ្នាក់នៃអំពើហឹង្សា[២០] គឺមានកំរិតខ្ពស់។ តែដោយសារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានគេបង្កើតឡើង ហើយតុលាការនេះកំពុងបំពេញប្រតិបត្តិការដំបូង ដើម្បីបញ្ចប់និទណ្ឌភាពដែលច្បាស់ក្រឡែតទៅហើយក្រោយរយៈពេល៣០ឆ្នាំ។ ការទុកចិត្តលើតុលាការដែលមានសមាសភាពបុគ្គលិកអន្តរជាតិធានាឱ្យសង្គមកម្ពុជាកាន់តែមានសង្ឃឹមឡើងជាងមុនថែមទៀតលើនីតិរដ្ឋ និងក្នុងការតស៊ូប្រឆាំងនិទណ្ឌភាព ហើយមួយវិញទៀត បង្កើនទូវគ្រោះថ្នាក់នៃការរំលោភបំពានប្រសិនបើជនត្រូវចោទនឹងត្រូវគេដោះលែង។

ទោះបីគ្មានការគំរាមគំហែងប្រឆាំងនឹងជនត្រូវចោទមុនពេលចាប់ខ្លួនក៏ដោយ មិនមានន័យថាការដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ននោះ នឹងត្រូវគេទទួលដោយសង្គមកម្ពុជា ដោយគ្មានការប្រឆាំងតវ៉ា ជាមួយការមិនទាន់យល់ដឹង (ការដោះលែងឱ្យនៅក្រៅឃុំ) ច្បាស់លាស់នោះទេ។

ដូចអង្គបុរេជំនុំជម្រះបានចង្អុលបង្ហាញនៅក្នុងសេចក្តីសំរេច[២១] របស់ខ្លួន អំពីបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ ការព្រួយបារម្ភជាក់លាក់ និងចលនានៅក្នុងសង្គមកម្ពុជា គឺច្បាស់ក្រឡែតពេករហូតដល់ការគ្រោះថ្នាក់ទាំងសុវត្ថិភាពរបស់ជនត្រូវចោទ និងសណ្តាប់ធ្នាប់សាធារណៈ គឺជាគ្រោះថ្នាក់ពិតប្រាកដ។

[២០] ចូរមើលវាក្យខ័ណ្ឌ៧១ ៧២ និងពីលេខ៧៧ ដល់ ៨១ នៃសេចក្តីសម្រេចរបស់ អ.ប.ជ រឿងក្តីរបស់លោក នួន ជា សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់លោក នួន ជា រឿងក្តីលេខ ០២/១៩-០៩-២០០៧-អ.វ.ត.ក/សហចៅក្រមស៊ើបអង្កេត (អ.ប.ជ (០១) ក្រោយមកទៀត "លោកនួន ជា ប្តឹងឧទ្ធរណ៍នឹង សេចក្តីសម្រេចនេះ"

[២១] សូមមើលវាក្យខ័ណ្ឌ៤២ ៤៣ ៤៨ ៤៩ អំពីសារណារបស់សហព្រះរាជអាជ្ញា

00181306



បន្ថែមពីលើនេះ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ស្របត្រង់ចំនុចនេះថាសេចក្តីថ្លែងរបស់សហព្រះរាជអាជ្ញាសមហេតុផល[២២] ។

២១. ទោះជាមានកង្វះខាតអង្គហេតុគ្រប់គ្រាន់ ក្នុងការប៉ាន់ប្រមាណដោយការិយាល័យសហចៅក្រមស៊ើបអង្កេត គឺមិនមែនជាកំហុសដែលប្តឹងឧទ្ធរណ៍បានទេ ។

**គ- ការគំរាមកំហែងដល់ជនរងគ្រោះនិងសាក្សី ដោយជនត្រូវចោទ ឬអ្នកដែលគាំទ្រជនត្រូវចោទ**[២៣]

២២. មេធាវីការពារផ្តល់ទឡ្ហីករណ៍ថាការិយាល័យសហចៅក្រមស៊ើបអង្កេតមិនបានផ្តល់ភស្តុតាងអំពីការគំរាមកំហែងដល់ជនរងគ្រោះនិងសាក្សីឡើយ ។

ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនមានភស្តុតាងដែលថា ជនត្រូវចោទបានគំរាមគំហែង ឬបានរំខានរួចហើយដល់ជនរងគ្រោះ និងសាក្សីនៅក្នុងអតីតកាល ប៉ុន្តែប្រការនេះមិនមានន័យថា ការប្រកែករបស់ជនជាប់ចោទនឹងមិនព្យាយាមនៅពេលអនាគតក្នុងការជ្រៀតជ្រែកពួកគេនោះទេ ។ ក្នុងអំឡុងពេលដ៏យូរឆ្នាំនៃការចរចារដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គេមិនរំពឹងថា តុលាការនេះនឹងត្រូវគេប្រើសំរាប់ដំណើរការនេះទាល់តែសោះ ហើយដូច្នេះមិនមាន "ការចំបាច់" បំភ័យសាក្សីក្នុងអតីតកាលនោះទេ ។ បច្ចុប្បន្ន ជនត្រូវចោទមានសិទ្ធិចូលរកឯកសារ និងដឹងច្បាស់អំពីអត្តសញ្ញាណរបស់សាក្សី និងជនរងគ្រោះ ។ ចូរកុំមើលងាយឱ្យសោះនូវការគោរព ឥទ្ធិពល និងអំណាចដែលជនត្រូវចោទនៅតែទទួលបានផ្នែកខ្លះនៅក្នុងសង្គមកម្ពុជា ដោយសារតែតំណែងអតីតជារដ្ឋមន្ត្រី ហើយនិងទំនាក់ទំនងជាច្រើនរបស់ជនត្រូវចោទទៅនឹងអ្នកមានអំណាច ។

កូនប្រុសរបស់ជនត្រូវចោទលោក អៀង វុធ គឺជាអភិបាលរងក្រុងប៉ៃលិន ។ អភិបាលក្រុងប៉ៃលិន និងអភិបាលរងដែលត្រូវតែងតាំងដោយរដ្ឋាភិបាលកម្ពុជាដែលកំពុងកាន់អំណាច មានឥទ្ធិពល និងអំណាច ជាចំបាច់ដើម្បីការពារជនត្រូវចោទ កុំឱ្យទទួលការកាត់ទោសនៅតុលាការនេះ ។ ជនរងគ្រោះ និងសាក្សី អាចអស់ជំនឿក្នុងការបង្ហាញសក្ខីភាព ។

---

[២២] សូមមើលវាក្យខ័ណ្ឌពី៤៨ ដល់ ៥៤ នៃបណ្តឹងឧទ្ធរណ៍

[២៣] ចូរមើលការស្ទង់មតិចុងក្រោយរបស់សហរដ្ឋអាមេរិកនៅក្នុងខេមបូឌៀរដេលី ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨ ទំព័រ២៧ "រដ្ឋាភិបាលបដិសេធការវាយតម្លៃសិទ្ធិមនុស្សរបស់សហរដ្ឋអាមេរិក" ដោយ Douglas Gillison ដកស្រង់ចេញពី " កំរងសិទ្ធិមនុស្សធានាការពារ ដូចជាសេរីភាពពីការមិនមានជីវិតស្របច្បាប់ ការជំនុំជម្រះជាសាធារណៈដ៏យុត្តិធម៌ និងសេរីភាពក្នុងការបញ្ចេញមតិយោបល់.......

២៣. ក្នុងប្រទេសកម្ពុជា ការការពារជនរងគ្រោះ និងសាក្សី គឺនៅខ្សោយនៅឡើយ ហើយនៅក្រៅតុលាការវិញ គឺមិនធានាបានទាល់តែសោះហើយ។ គ្រោះថ្នាក់មានកំរិតខ្ពស់គួរសមដែរ ដែលការគំរាមគំហែងតែមួយមុខអាចរារាំងអ្នកដទៃទៀតមិនឱ្យផ្តល់សាក្សីភាពនៅក្នុងដំណើរការកាត់ក្តីខាងមុខ ។ ដូចបានគូសបញ្ជាក់ នៅក្នុងការវាយតម្លៃចុងក្រោយរបស់សហរដ្ឋអាមេរិកស្តីពី សិទ្ធិមនុស្ស និងនីតិរដ្ឋ អាជ្ញាធរកម្ពុជាមិនមានគោលជំហរយកអ្នកបំភិតបំភ័យដែលមានឥទ្ធិពលមកកាត់ទោសឱ្យមានប្រសិទ្ធិភាពនៅឡើយ។

ដូច្នេះទឡ្ហីករណ៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលថាវាគឺជាការភ័យខ្លាចដ៏ពិតប្រាកដមួយនៃការដាក់សំពាធ ដោយសារដំណើរការស៊ើបអង្កេតបានធ្វើឡើង ហើយឯកសារ គឺបានបើកចំហរដល់ជនត្រូវចោទ គឺគ្រប់គ្រាន់ដើម្បីពិចារណាថាការឃុំខ្លួនបណ្តោះអាសន្ន គឺជាការចំបាច់[២៤] ។

២៤. លើសពីនេះទៅទៀត សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រង់ចំនុចនេះយល់ស្របតាមសារណាដ៏សមស្របរបស់សហព្រះរាជអាជ្ញា[២៥] ។

២៥. បន្ថែមពីនេះ ជំហររបស់មេធាវីការពារមិនបានលើកឡើងអំពីកំហុសណាមួយ នៃការប្តឹងឧទ្ធរណ៍ក្នុងការប្រើឆន្ទានុសិទ្ធិស្តីពីសេចក្តីសម្រេចដែលមានមន្ទិលសង្ស័យនោះទេ។

**ឃ. ការមិនចូលរួមជំនុំជម្រះ[២៦]**

២៦. ទឡ្ហីករណ៍របស់មេធាវីការពារ មិនបានបង្ហាញឱ្យឃើញថាការិយាល័យសហចៅក្រមស៊ើបអង្កេតប្រព្រឹត្តខុសក្នុងការវាយតម្លៃអង្គហេតុ ហើយថាសេចក្តីសម្រេចរបស់ខ្លួនមិនអាចទទួលយកបានសំរាប់ជាសំអាងនោះទេ[២៧] ។ បើសិនជនត្រូវចោទអាចរត់គេចខ្លួន ការវាយតម្លៃស្នើសុំឱ្យមានការត្រិះរិះពីការខ្វែងគំនិតគ្នាដោយផ្អែកលើទឡ្ហីករណ៍។ ការដោះស្រាយសេចក្តីសម្រេចដើម្បីផ្តល់ ឬបដិសេធឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ទាក់ទិនបញ្ហាជាច្រើនដែលមិនអាចផ្តល់ភស្តុតាងបាន ប៉ុន្តែត្រូវឈរលើមូលដ្ឋានដ៏រឹងមាំគួរឱ្យជឿបាន ។

[២៤] ចូរមើលវាក្យខ័ណ្ឌពី២៦ ដល់ ២៩ នៃសារណារបស់សហព្រះរាជអាជ្ញា

[២៥] ចូរមើលវាក្យខ័ណ្ឌពី២៦ ដល់ ២៩ នៃសារណារបស់សហព្រះរាជអាជ្ញា

[២៦] ចូរមើលសេចក្តីសម្រេចនៅក្រៅឃុំបណ្តោះអាសន្នរបស់ Fofana វាក្យខ័ណ្ឌ២១

[២៧] ចូរមើលវាក្យខ័ណ្ឌពី៣៣ ដល់ ៣៦

00181308

C2012/17

២៧. ការិយាល័យសហចៅក្រមស៊ើបអង្កេតពឹងផ្អែកលើអង្គហេតុថា ជនត្រូវចោទដែលរំពឹងថាមានការរស់នៅបរទេស ធ្វើដំណើរច្រើននៅបណ្តាប្រទេសដែលមិនមានកិច្ចព្រមព្រៀងបត្យាប័នជាមួយកម្ពុជា ហើយថាជនត្រូវចោទមានមធ្យោបាយសម្ភារៈក្នុងការរត់គេចខ្លួន ប្រសិនបើត្រូវគេកាត់ទោសដាក់គុកមួយជីវិត។ មូលហេតុទាំងនេះច្បាស់ណាស់ដើម្បីបង្ហាញថាមានមូលហេតុគ្រប់គ្រាន់ដែលជឿថា ជនត្រូវចោទអាចគេចខ្លួនប្រសិនបើត្រូវដោះលែង។ ឆន្ទានុសិទ្ធិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវបានអនុវត្តសមហេតុផល។

២៨. គួរកត់សំគាល់ផងដែរថា អ្នកដែលរស់នៅក្រុងប៉ៃលិនមានសិទ្ធិទទួលបាននូវអ្វីដែលហៅថា "ប័ណ្ណឆ្លងដែនពិសេស" ដែលត្រូវគេទទួលស្គាល់ដោយការអនុញ្ញាតិឱ្យឆ្លងកាត់ព្រំដែន សូម្បីមិនមានលិខិតឆ្លងដែន ឬ ទិដ្ឋាការក៏ដោយ។

នៅពេលណាដែលជនត្រូវចោទត្រូវបានគេដោះលែង គ្រួសាររបស់ជនត្រូវចោទមានចំណងទាក់ទងនៅក្រុងប៉ៃលិនអាចលៃលកឱ្យជនត្រូវចោទ ចាកចេញពីប្រទេសយ៉ាងងាយស្រួល។

ជាងនេះទៅទៀត ក្នុងករណីមានការដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន អាជ្ញាធរកម្ពុជាមិនមានមធ្យោបាយគ្រប់គ្រាន់ដើម្បីធានាថាជនត្រូវចោទមិនរត់គេចខ្លួន ឬដើម្បីស្រាវជ្រាវឱ្យមានប្រសិទ្ធិភាពទេ។

២៩. មេធាវីការពារជំទាស់ទៅនឹងមូលហេតុទាំងនេះដោយគូសបញ្ជាក់ថា ជនត្រូវចោទមានចំណងគ្រួសាររឹងមាំ មិនមានការលាក់បំពួនពីមុនមក និងមានវ័យចំណាស់ដែលចាំបាច់ត្រូវការការព្យាបាលជម្ងឺ ហើយថាជនត្រូវចោទតែងតែត្រឡប់មកពីប្រទេសថៃវិញ។

មេធាវីការពារមិនផ្តល់ទឡ្ហីករណ៍អំពីអង្គហេតុដែលបានដាក់ដោយសហចៅក្រមស៊ើបអង្កេតទាក់ទងទៅនឹងមធ្យោបាយហិរញ្ញវត្ថុ លំនៅដ្ឋាននៅបរទេស និងការធ្វើដំណើរទៅបរទេសរបស់ជនត្រូវចោទដោយគ្មានកិច្ចព្រមព្រៀងបត្យាប័នជាមួយប្រទេសកម្ពុជា។ ដូច្នេះគេសន្និដ្ឋានថា អង្គហេតុទាំងនេះពិតជាត្រឹមត្រូវ។

៣០. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រនូវសារណាបន្ថែមរបស់សហព្រះរាជអាជ្ញានៅត្រង់ចំនុចនេះ[២៨]។

៣១. មេធាវីការពារពិតជាមិនបានផ្តល់នូវទឡ្ហីករណ៍របស់ខ្លួនទេ ពីព្រោះការរំលោភឆន្ទានុសិទ្ធិមិនបានលើកឡើងឱ្យបានច្បាស់លាស់នោះទេ។

[២៨] ចូរមើលវាក្យខ័ណ្ឌ៣៨ នៃបណ្តឹងឧទ្ធរណ៍

00181309

E20/I/17

**ង. បន្ទុកនៃភស្តុតាង**[២៩]

៣២. មេធាវីការពារភាន់ច្រឡំនូវទស្សនៈរបស់ខ្លួនដែលថា ក្នុងសេចក្តីសម្រេចផ្តល់ ឬបដិសេធការឱ្យនៅក្រៅឃុំបណ្តោះអាសន្ន "វាផ្ទុយទៅនឹងច្បាប់កម្ពុជាដែលបន្ទុកភស្តុតាងពឹងផ្អែកលើព្រះរាជអាជ្ញា" ។

៣៣. មិនមាននៅក្នុងច្បាប់កម្ពុជា ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌពាក់ព័ន្ធ ហើយព្រមទាំងមិនមាននៅក្នុងវិធានផ្ទៃក្នុង ដែលជាបញ្ញត្តិមួយអំពីបន្ទុកនៃភស្តុតាងនៅក្នុងសំណួរនៃលក្ខខណ្ឌក្នុងវិធាន៦៣ (៣) នៃវិធានផ្ទៃក្នុង។ ក្នុងករណីចន្លោះប្រហោង វិធាននីតិវិធីក្នុងកិរិតអន្តរជាតិដែលពាក់ព័ន្ធ និងផ្តល់ជាគោលការណ៍ណែនាំ ។

៣៤. ទោះបីជាក្នុងវិធានសាលាក្តីព្រហ្មទណ្ឌអន្តរជាតិអតីតយូហ្គោស្លាវី (ហើយបន្ទាប់មកទៀតសាលាក្តីព្រហ្មទណ្ឌអន្តរជាតិអតីតរ៉្វាន់ដា) គឺមិនមានតម្រូវការទៀតទេសំរាប់ជនជាប់ចោទដើម្បីបង្ហាញអំពី "ករណីពិសេស" មុនពេលគេអនុញ្ញាតិឱ្យមានការដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ។ ប៉ុន្តែសាលាក្តីព្រហ្មទណ្ឌអន្តរជាតិអតីតយូហ្គោស្លាវីរក្សានូវតំរូវការនេះចំពោះសំណួរនៃការដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ហើយដាក់បន្ទុកលើជនជាប់ចោទដើម្បីបង្កើតឱ្យមានសិទ្ធសុំដោះលែងបណ្តោះអាសន្ន[៣០] ។ ការដាក់បន្ទុកភស្តុតាងលើជនត្រូវចោទ គឺមិនមែនជាការរំលោភនៃគោលការណ៍សន្មត់ជាមុនថាគ្មានទោសដូចមេធាវីការពារលើកឡើងនោះទេ។ បញ្ហានេះនៅក្នុងសំនួរ ប្រសិនបើជនត្រូវចោទអាចត្រូវបានគេដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ហើយត្រូវពិចារណាថា ប្រសិនបើលក្ខខណ្ឌតំរូវជាមុន

---

[២៩] ព្រះរាជអាជ្ញាលោក v. Radoslav Brdanin & Momir Talic, ICTY, សភាជាន់ខ្ពស់ រឿងក្តីលេខ IT-99-36 សេចក្តីសម្រេចស្តីពីការដាក់ពាក្យសុំលុបចោលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ២០០០ ចូរមើល Fofana, សេចក្តីសម្រេចសុំនៅក្រៅឃុំបណ្តោះអាសន្ន វាក្យខ័ណ្ឌ៣៦

00181310

C2015/17

មួយក្នុងវិធានផ្ទៃក្នុង ៦៣ (ខ) អនុវត្ត និងបង្ហាញឱ្យឃើញថាការឃុំខ្លួន ឬមិនឃុំខ្លួនត្រឹមត្រូវ។ ហើយបញ្ហានេះស្ថិតនៅលើជនត្រូវចោទធ្វើឱ្យអង្គបុរេជំនុំជម្រះយល់ព្រមសម្រេចបង្គាប់ឱ្យដោះលែងក្រៅឃុំបណ្តោះអាសន្ន។ ប៉ុន្តែបន្ទុកនៃការបង្ហាញភស្តុតាងនេះ មិនប៉ះពាល់ដល់ការសន្មត់ជាមុនថាគ្មានទោស ហើយជាការពិតបន្ទុកនេះត្រូវតែបង្ហាញឱ្យឃើញ។

**ច. ស្ថានភាពសុខភាព**

៣៥. លិខិតបញ្ជាក់អំពីសុខភាពដែលបញ្ជូនមក មិនបានចង្អុលបង្ហាញថាជនត្រូវចោទគួរឱ្យដោះលែងនៅក្រៅឃុំបណ្តោះអាសន្នចំពោះមូលហេតុទាំងនេះឡើយ។ ជនត្រូវចោទអាចទទួលការពិនិត្យព្យាបាលជម្ងឺជាចាំបាច់នៅក្នុងអំឡុងពេលឃុំខ្លួន។

**VIII- សន្និដ្ឋាន**

36. បណ្តឹងឧទ្ធរណ៍មិនមានមូលហេតុគ្រប់គ្រាន់នោះទេ។ ដីកាឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត គឺសមហេតុសមផល មានមូលហេតុគ្រប់គ្រាន់ ហើយឆន្ទានុសិទ្ធិនេះត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ។

**<u>យោងតាមហេតុផលទាំងនេះ</u> :**

**សូមអង្គបុរេជំនុំជម្រះ**

**បដិសេធបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារចោលជាអសារបង់**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោក ហុង គីមសួន
មេធាវីមកពី ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
[signature]

លោក នី ចាន់ឌី
មេធាវីមកពី អង្គការជំនួយ ផ្នែកច្បាប់ នៃកម្ពុជា
[signature]

លោក ឡោ ជុនធី
មេធាវីមកពី អង្គការជំនួយ ផ្នែកច្បាប់ នៃកម្ពុជា
[signature]

លោកស្រី Silke Studzinsky
[signature]

ធ្វើនៅភ្នំពេញ. ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០៨